00328077

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

C26/5/22

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ១៤ និង ១៥)

ចំពោះមុខ: ចៅក្រម ប្រាក់ គីមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន័យ ធុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ១៩ ឧសភា ២០០៩

---

សាធារណៈ

ការព្រមានចំពោះសហមេធាវីអន្តរជាតិ

---

**ការិយាល័យសហព្រះរាជអាជ្ញា**

ជា លាង
Robert PETIT
យ៉ែត ចរិយា
William SMITH
ពេជ្រ សម្បត្តិ
Vincent de WILDE d'ESTMAEL

**ជនត្រូវចោទ**

ខៀវ សំផន

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ហុង គីមសួន
ឡោ ជុនធី
នី ចាន់ឌី
គង់ ពិសី
យុង ផានិត
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUZINSKY
Martine JACQUIN
Philippe CANNONE
Pierre Olivier SUR
Elizabeth RABESANDRATANA
Olivier BAHOUGNE
David BLACKMAN

**សហមេធាវីការពារក្តី**

ស សុវាន
Jacques VERGÈS

ឯកសារបានចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 20 / 05 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A. Fuy

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 19 / 05 / 2009
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A. Fuy

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C.

00328078



១. **អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បន្ទាប់ពីបានទទួលពីសហមេធាវីការពារក្តីជនត្រូវចោទ នូវពាក្យបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើសុំដោះលែង ចុះថ្ងៃទី២៧ ខែ វិច្ឆិកា ឆ្នាំ២០០៨ (អបជ ១៤ ) និងពាក្យបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចបន្តថិរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៨ (អបជ ១៥) ("បណ្តឹងឧទ្ធរណ៍") ដែលត្រូវបានធ្វើសវនាការ កាលពីថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៩។

## I- ប្រវត្តិ

២. នៅក្នុងចម្លើយតបរបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញាបានស្នើដល់អង្គបុរេជំនុំជម្រះ សុំឲ្យសម្រេចលើបណ្តឹងឧទ្ធរណ៍ ដោយផ្អែកលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ[1]។

៣. ដោយអនុវត្តតាមការអញ្ជើញរបស់អង្គបុរេជំនុំជម្រះ សហមេធាវីការពារក្តីជនត្រូវចោទបានដាក់ចម្លើយតបមួយ ដែលក្នុងនោះសហមេធាវីការពារក្តីជនត្រូវចោទ "បានប្រឆាំងដាច់ខាត" ទៅនឹងសំណើសុំនោះ និងបានស្នើអង្គបុរេជំនុំជម្រះឲ្យកំណត់កាលបរិច្ឆេទសវនាការសាធារណៈ ដើម្បីជជែកដេញដោលលើបណ្តឹងឧទ្ធរណ៍ទាំងពីរ។ សហមេធាវីការពារក្តីបានតវ៉ាថា បណ្តឹងឧទ្ធរណ៍ទាំងពីរពាក់ព័ន្ធនឹងអនីត្យានុកូលភាពនៃការឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្ន និងសេចក្តីត្រូវការឲ្យមានការដោះលែងជាបន្ទាន់របស់ជនត្រូវចោទ។ សហមេធាវីការពារក្តីបានលើកឡើងថា បណ្តឹងឧទ្ធរណ៍ទាំងនេះបានលើកឡើងនូវបញ្ហាផ្លូវច្បាប់ថ្មីៗ ព្រមទាំងពាក់ព័ន្ធនឹងសិទ្ធិជាមូលដ្ឋានក្នុងការមានសេរីភាពរបស់ជនត្រូវចោទ។ សហមេធាវីការពារក្តីបានស្នើថា សវនាការគួរត្រូវបានកំណត់កាលបរិច្ឆេទឲ្យបានឆាប់រហ័សតាមលទ្ធភាពដែលអាចធ្វើទៅបាន[2]។

---

[1] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសារណាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបដិសេធការដោះលែងឲ្យមានសេរីភាព ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨, ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៩, C40/5/2, កថាខណ្ឌទី៦, និង ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨, ចុះថ្ងៃទី៩ ខែមករា ឆ្នាំ២០០៩, C26/5/10, កថាខណ្ឌទី៤។

[2] ចម្លើយតបរបស់ក្រុមការពារក្តីទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យសម្រេចសេចក្តីលើសារណាជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ, ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៩, C26/5/12, កថាខណ្ឌទី២, ២២ និង២៣, និងទំព័រទី៨។
ការព្រមានចំពោះសហមេធាវីអន្តរជាតិ

៤. អង្គបុរេជំនុំជម្រះបានទទួលស្គាល់សារៈសំខាន់នៃបណ្តឹងឧទ្ធរណ៍ទាំងពីរ ដែលបណ្តឹងទាំងពីរនេះមានការពាក់ព័ន្ធនឹងសេរីភាពរបស់ជនត្រូវចោទ និងបានពិចារណាលើសំណើរបស់សហមេធាវីការពារក្តីសុំឲ្យមានការជជែកដេញដោលដោយផ្ទាល់មាត់ ក៏ដូចជាសិទ្ធិទូទៅរបស់ជនត្រូវចោទត្រូវយកមកជជែកដេញដោល ព្រមទាំងបានកំណត់កាលបរិច្ឆេទសវនាការលើបណ្តឹងឧទ្ធរណ៍ទាំងនេះនៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ ២០០៨ វេលាម៉ោង៩:00 ព្រឹក[3]។

៥. នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានទទួលសំណើមួយពីសហមេធាវីជាតិ សុំឲ្យពន្យារពេលចាប់ផ្តើមសវនាការនាថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៨ ចំនួន១ម៉ោង។ សំណើនេះបានលើកឡើងដោយសារកាលៈទេសៈពិសេសរបស់លោក Jacques Vergès សហមេធាវីអន្តរជាតិ ដែលជើងយន្តហោះរបស់គាត់ត្រូវពន្យារពេល ហើយគាត់នឹងមកដល់ភ្នំពេញនៅម៉ោង៩:00 ព្រឹក នាថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៨[4]។ សំណើសុំនេះត្រូវបានផ្តល់ឲ្យ រីឯសវនាការត្រូវបានកំណត់ពេលវេលាសារជាថ្មី ដោយចាប់ផ្តើមនៅម៉ោង១០:00ព្រឹក[5]។

៦. នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៨ នៅពេលបើកសវនាការ ជនត្រូវចោទ និងសហមេធាវីជាតិរបស់ខ្លួន បានស្នើសុំឲ្យលើកពេលសវនាការទៅថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៨ វិញ ដោយមូលហេតុថា លោក Jacques Vergès មិនអាចមកចូលរួមបាន។ ដើម្បីគាំទ្រដល់សំណើសុំលើកពេលសវនាការនេះ សហមេធាវីជាតិបានតវ៉ាជាពិសេសថា គាត់បាន "នឹងកំពុងការពារពាក្យបណ្តឹងឧទ្ធរណ៍មួយ ខណៈពេលដែលលោក Jacques Vergès [បាននឹង] កំពុងការពារពាក្យបណ្តឹងឧទ្ធរណ៍មួយទៀត ពាក់ព័ន្ធនឹងការឃុំខ្លួនបណ្តោះអាសន្ន"[6]។ មិនមានភាពច្បាស់លាស់អំពីមូលហេតុដែលលោក Jacques Vergès មិនអាចមកដល់នាព្រឹកថ្ងៃទី២៧ ខែកុម្ភៈ ដូចបានបង្ហាញកាលពីថ្ងៃមុននោះទេ ឬក៏អំពីមូលហេតុដែលអង្គបុរេជំនុំជម្រះ មិនត្រូវបានគេជូនដំណឹងអំពីការអវត្តមានរបស់លោក Jacques Vergès នៅដំណាក់កាលមួយដែលលឿនជាងនេះទេ។

---

[3] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាដើម្បីកំណត់លើបណ្តឹងឧទ្ធរណ៍ដោយផ្អែកលើមូលដ្ឋាននៃសារណាជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ និងដីកាកំណត់កាលបរិច្ឆេទសវនាការ, ចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០០៨, C26/5/13។

[4] សំណើសុំលើកម៉ោងបើកសវនាការថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៨, ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៨, C26/5/17។

[5] សេចក្តីសម្រេចលើសំណើរបស់ក្រុមមេធាវីការពារក្តី សុំលើកពេលបើកសវនាការ និងដីកាសម្រេចកែប្រែកាលបរិច្ឆេទសវនាការ, ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៨, C26/5/18។

[6] ប្រតិចារឹក, ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៨, ទំព័រទី៣។

ពុំមានព័ត៌មានណាមួយ ត្រូវផ្តល់ឱ្យដោយផ្ទាល់ពីសហមេធាវីអន្តរជាតិនៅពេលនោះ ឬនៅពេលបន្ទាប់មកទៀតទេ។

៧. អង្គបុរេជំនុំជម្រះ បានលើកពេលសវនាការទៅថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៨ វិញ តាមរយៈសេចក្តីសម្រេចដែលធ្វើដោយផ្ទាល់មាត់នៅក្នុងពេលសវនាការកាលពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៨ ដោយឈរលើមូលដ្ឋានថា ទោះបីជាវាជាផលប្រយោជន៍របស់ជនត្រូវចោទ ក្នុងការដំណើរការឱ្យបានឆាប់រហ័សតាមលទ្ធភាព ដោយសារតែពាក្យបណ្តឹងឧទ្ធរណ៍របស់គាត់មានការពាក់ព័ន្ធនឹងសេរីភាពរបស់គាត់ក៏ដោយ ជនត្រូវចោទខ្លួនឯងនិងសហមេធាវីជាតិរបស់គាត់ បានស្នើដល់អង្គបុរេជំនុំជម្រះ សុំកុំឱ្យដំណើរការនីតិវិធីដោយអវត្តមានសហមេធាវីអន្តរជាតិ។ សេចក្តីសម្រេចនេះ ត្រូវបានបញ្ជូនចេញជាលាយលក្ខណ៍អក្សរនៅក្នុងថ្ងៃដដែល[7]។

៨. នៅថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានបើកសវនាការ ដោយចាប់ផ្តើមពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើសុំដោះលែង។

៩. បន្ទាប់ពីសហមេធាវីជាតិបានធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់ខ្លួន ពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍នេះរួចមក លោក Jacques Vergès បានប្រកាសថា:

> "លោក Jacques Vergès [ការបកប្រែពីភាសាបារាំង]៖
>
> មិត្តរបស់ខ្ញុំ លោក សូវ៉ាន បាននិយាយក្នុងនាមសហមេធាវីការពារក្តី។ សហមេធាវីការពារក្តីមានគោលជំហរួមគ្នា។ ដូច្នេះ លោក សូវ៉ាន បាននិយាយនូវអ្វីដែលខ្ញុំបានគិត ហើយខ្ញុំមានអារម្មណ៍ថាមិនចាំបាច់និយាយឡើងវិញនូវអ្វីដែលគាត់បាននិយាយរួចហើយនោះទេ"[8]។

---

[7] សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរនៃសេចក្តីសម្រេចដោយផ្ទាល់មាត់ លើសំណើរបស់ក្រុមមេធាវីការពារក្តី សុំលើកពេលបើកសវនាការ, ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៨, C26/5/19, កថាខណ្ឌទី៤។

[8] ប្រតិចារឹក, ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៨, ទំព័រទី២៤។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C.

១០. នៅពេលនោះ សហព្រះរាជអាជ្ញាបានធ្វើសេចក្ដីសន្និដ្ឋានផ្ទាល់មាត់ពាក់ព័ន្ធនឹងបណ្ដឹងឧទ្ធរណ៍នេះ ដោយបានជជែកពិភាក្សាអំពីការបំពេញលក្ខខណ្ឌ ក្នុងការបង្គាប់ឱ្យមានការឃុំខ្លួនបណ្ដោះអាសន្ន ដែលបានចែងនៅក្នុងវិធាន ៦៣ នៃវិធានផ្ទៃក្នុង។

១១. ដោយត្រូវបានផ្ដល់ឱកាសឱ្យ ដើម្បីឆ្លើយតបចំពោះសេចក្ដីសន្និដ្ឋានផ្ទាល់មាត់របស់សហព្រះរាជអាជ្ញាវិញនោះ លោក Jacques Vergès បាននិយាយថា៖

> "លោក Jacques Vergès [ការបកប្រែពីភាសាបារាំង]៖
> ពួកយើងបានស្នើដល់សហចៅក្រមស៊ើបអង្កេតឱ្យផ្ដល់ព័ត៌មាន ពាក់ព័ន្ធនឹងដំណើរការនីតិវិធីដោយចាប់ផ្ដើមពីបញ្ហាអំពើពុករលួយ ហើយចំពោះកម្មវត្ថុនេះ ខ្ញុំប្រហែលជាអាចធ្វើការពន្យល់បានខ្លះ"[9]។

១២. លោក Jacques Vergès ត្រូវបានបង្អាក់ដោយចៅក្រម Downing ដែលបាននិយាយថា សហមេធាវីការពារក្ដី បាននឹងកំពុងលើកឡើងនូវបញ្ហាថ្មីៗ និងថាបញ្ហានេះមិនត្រូវបានអនុញ្ញាតឱ្យលើកឡើងនោះទេ។ គាត់បានគូសបញ្ជាក់ថា សហមេធាវីការពារគួរតែលើកឡើងនូវអ្វីដែលជាការឆ្លើយតបចំពោះសេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាតែប៉ុណ្ណោះ។

១៣. លោក Jacques Vergès បានឆ្លើយតបដូចខាងក្រោម៖

"លោក Jacques Vergès [ការបកប្រែពីប្រតិចារឹកជាភាសាបារាំង]៖

> [ការចាប់ផ្ដើមមិនអាចឮបាន] ... ជាបឋម ខ្ញុំនឹងមិនលើកឡើងនូវបញ្ហាថ្មីនោះទេ ខ្ញុំនឹងធ្វើតាមសេចក្ដីសម្រេចរបស់តុលាការ ប៉ុន្តែសូមអនុញ្ញាតឱ្យខ្ញុំពន្យល់អំពីមូលហេតុ។ ខ្ញុំពុំគួរនិយាយបញ្ហានេះទេ ដូចដែលតុលាការបានអនុញ្ញាតឱ្យដើមបណ្ដឹងរដ្ឋប្បវេណីធ្វើកាលពីព្រឹកមិញ។ ខ្ញុំនឹងសង្ខេបឱ្យបានខ្លី។ ជាដំបូង ខ្ញុំត្រូវតែរក្សាការស្ងៀមស្ងាត់ ពីព្រោះខ្ញុំមិនព្រួយបារម្ភអំពីអង្គជំនុំជម្រះ ច្រើនជាងអង្គជំនុំជម្រះខ្លួនឯងនោះទេ។ ប្រសិនបើអង្គជំនុំជម្រះពិចារណាឃើញថា មិនគួរលើកយកអំពើពុករលួយមកធ្វើការពិភាក្សាទេនោះ ខ្ញុំនឹងមិនបង្ខំឱ្យអង្គជំនុំជម្រះធ្វើការពិភាក្សានោះទេ។ ខ្ញុំត្រូវតែរក្សារការស្ងៀមស្ងាត់ ពីព្រោះខ្ញុំយល់អំពីការហាមឃាត់របស់អង្គជំនុំជម្រះពាក់ព័ន្ធនឹងបញ្ហានេះ ហើយខ្ញុំគិតថា ការសន្មតទុកជាមុនថាគ្មានទោសដែលអង្គជំនុំជម្រះពេលខ្លះបានបដិសេធ ជួនគ្រាវចៅទនោះ

[9] ប្រតិចារឹក, ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៨, ទំព័រទី៤៦។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C.

អាចជាប្រយោជន៍មួយចំនួនរបស់អង្គជំនុំជម្រះ។ ហើយខ្ញុំត្រូវតែរក្សាការស្ងៀមស្ងាត់ ពីព្រោះប្រមុខរដ្ឋដែលជាម្ចាស់ផ្ទះរៀបចំអង្គជំនុំជម្រះ បានមានប្រសាសន៍ជាសាធារណៈថា គាត់ប្រាថ្នាចង់ឲ្យអង្គជំនុំជម្រះចាកចេញ ហាក់ដូចជានិយាយដោយមានសីលធម៌ថា អ្នកជាអ្នកអនាធិប្បតេយ្យ។ ខ្ញុំត្រូវតែរក្សារការស្ងៀមស្ងាត់ផងដែរ ពីព្រោះសមាជិករដ្ឋាភិបាលរបស់ប្រទេស ដែលរៀបចំអង្គជំនុំជម្រះបាននិយាយថា អង្គជំនុំជម្រះមើលឃើញតែលុយប៉ុណ្ណោះ ដែលជាការអះអាងគាំទ្រដល់ការចោទប្រកាន់នានា - ទោះមានភស្តុតាងក៏ដោយ គ្មានក៏ដោយ ការលើកឡើងបែបនេះ - ពិតជាធ្វើឲ្យប៉ះពាល់តុលាការ។

ជាចុងក្រោយ - អង្គជំនុំជម្រះឃើញទេ ខ្ញុំនឹងសង្ខេបយ៉ាងខ្លី - ពីព្រោះវាហាក់ដូចជាមិនត្រូវបាញ់ទៅលើរថយន្តសង្គ្រោះ និងជនរងគ្រោះ និងអ្នករងរបួស។ វាក៏ហាក់ដូចជា មិនត្រូវបាញ់ទៅលើរថយន្តដឹកសព និងអ្នកជិតស្លាប់នោះដែរ”[10]។

១៤. នៅល្ងាចថ្ងៃដដែលនោះ អង្គបុរេជំនុំជម្រះបានចាប់ផ្តើមសវនាការលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន។ ជាថ្មីម្តងទៀត សហមេធាវីជាតិបានលើកឡើងនូវកំណត់សម្គាល់ផ្ទាល់មាត់របស់ខ្លួន ហើយនៅពេលដែលត្រូវគេផ្តល់ឱកាសឲ្យនិយាយលោក Vergès បានប្រកាសថា: “លោក ស សូវាន បាននិយាយរួចទៅហើយនូវអ្វីដែលខ្ញុំ បានគិត”[11]។

១៥. នៅក្នុងការឆ្លើយតបរបស់ខ្លួន សហព្រះរាជអាជ្ញាអន្តរជាតិ បានលើកឡើងអំពីអង្គហេតុថា សហមេធាវីការពារក្តីបាននឹងកំពុងប្រើប្រាស់វិធីសាស្ត្រនាំទៅបង្អាក់ដល់ដំណើរការនីតិវិធី។ សហព្រះរាជអាជ្ញាអន្តរជាតិបានយោងទៅលើកំណត់ហេតុដែលធ្វើដោយលោក Vergès នៅក្នុងកថាខណ្ឌទី១៣ ខាងលើ ដោយលើកឡើងថា:

“លោក DE WILDE D’ESTMAEL [ការបកប្រែពីភាសាបារាំង]០:

នេះគឺជាវិធីសាស្ត្រនៃការរាំងស្ទះរបស់សហមេធាវីការពារក្តី ដែលបានដាក់ជូនទឡ្ហីករណ៍តែមួយប៉ុណ្ណោះនៅក្នុងរយៈពេល១ឆ្នាំ ដែលជាទឡ្ហីករណ៍លើការបកប្រែភាសា ហើយបានបដិសេធ មិនសហការជាមួយអង្គជំនុំជម្រះវិសាមញ្ញ ជាពិសេសជាមួយផ្នែករដ្ឋបាល ឬសេវាកម្មនានារបស់តុលាការនេះ។ វិធីសាស្ត្រដែលសហមេធាវីអន្តរជាតិនេះ បានផ្អែកលើជំនាញទាំងអស់របស់ខ្លួន មានចេតនា

[10] ប្រតិចារឹកជាភាសាអង់គ្លេសបកប្រែពីភាសាបារាំង, ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៨, ទំព័រទី៥២ និង ៥៣។

[11] ប្រតិចារឹក, ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៨, ទំព័រទី៥៨។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

ទាំងស្រុងក្នុងការបង្អាក់ និងពន្យារពេលដំណើរការនីតិវិធី ដែលមិនធ្វើឱ្យសវនាការណាមួយ អាចត្រូវបានសម្រេចឱ្យបានតាមពេលវេលាដ៏សមស្របនោះទេ”[12]។

បន្ទាប់មក គាត់បានសួរថា: “តើអង្គជំនុំជម្រះនេះអាចបន្តអត់ធ្មត់នឹងវិធីសាស្ត្រនេះនៅចំពោះមុខ អ.វ.ត.ក បានដែរឬទេ?”[13]

ដោយបានគូសបញ្ជាក់ពី “អវត្តមាននៃកិច្ចសហការលើផ្នែកសហមេធាវីការពារក្តី និងការជជែកតវ៉ាជាលក្ខណៈប្រព័ន្ធអំពីសិទ្ធិអំណាចរបស់អង្គជំនុំជម្រះនេះ និងរបស់អ.វ.ត.កជាទូទៅ”នោះ[14] សហព្រះរាជអាជ្ញាអន្តរជាតិបានចោទសួរ អំពីភាពសមស្រប និងការប្រព្រឹត្តិរបស់សហមេធាវីការពារក្តី ចំពោះសំណុំរឿងនេះ។ គាត់បានសន្និដ្ឋានថា: “សំណួរដែលបានចោទសួរមានការពាក់ព័ន្ធនឹងអ្វី ដែលអង្គបុរេជំនុំជម្រះបានលើកឡើងនៅក្នុងពេលសវនាការកាលពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៨ ដែលជាសំខាន់ គឺដើម្បីស្វែងយល់ថាតើសហមេធាវីការពារក្តីបានត្រៀមខ្លួនរួចរាល់ដោយប្រសិទ្ធភាព ដើម្បីការពារសិទ្ធិរបស់កូនក្តី និងដើម្បីបំពេញការងារនោះដោយឧស្សាហ៍ព្យាយាមហើយឬនៅ”[15]។ សហព្រះរាជអាជ្ញាអន្តរជាតិ បានស្នើអង្គបុរេជំនុំជម្រះ សុំឱ្យទាញសេចក្តីសន្និដ្ឋាន ដែលចាំបាច់ទាំងអស់ដើម្បីរក្សាសិទ្ធិជាមូលដ្ឋានរបស់ជនត្រូវចោទ។

១៦. ដោយត្រូវបានផ្តល់ឱកាសដើម្បីឆ្លើយតបវិញនោះ លោក Jacques Vergès បាននិយាយថា:

> “ព្រះរាជអាជ្ញារងបានធ្វើការជជែកជាមួយខ្ញុំយ៉ាងសមសួន ហើយខ្ញុំត្រូវតែឆ្លើយតបដោយប្រើពាក្យស្លោកជាភាសាឡាតាំង: *ច្បាប់មិនយកចិត្តទុកដាក់ក្នុងរឿងកំប៉ិកកំប៉ុកនោះទេ (de minimis no curat praetor)*។ ខ្ញុំសង្ឃឹមថា គាត់ប្រាកដជាយល់ភាសាឡាតាំង”[16]។

---

[12] ប្រតិចារឹក, ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៩, ទំព័រទី៦៤។

[13] ប្រតិចារឹក, ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៩, ទំព័រទី៦៤។

[14] ប្រតិចារឹក, ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៩, ទំព័រទី៦៥។

[15] ប្រតិចារឹក, ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៩, ទំព័រទី៦៦។

[16] ប្រតិចារឹក, ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៩, ទំព័រទី៧៣។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C.

C26/5/22



## II. ការពិចារណា

១៧. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា វិធាន៣៨ នៃវិធានផ្ទៃក្នុងដែលបានចែងថា:

"វិធាន ៣៨៖ កំហុសវិជ្ជាជីវៈរបស់មេធាវី

១. សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ ក្រោយពេលព្រមាន អាចដាក់ទណ្ឌកម្ម ឬបដិសេធក្នុងការចូលរួមសវនាការចំពោះមេធាវីណាមួយ ប្រសិនបើយល់ឃើញថា ការប្រព្រឹត្តិរបស់មេធាវីរូបនោះជាការប្រមាថមើលងាយ រាំងស្ទះដល់កិច្ចដំណើរការនីតិវិធីរំលោភទៅលើរឿងក្ដី ឬផ្ទុយទៅនឹងមាត្រា ២១-៣ នៃកិច្ចព្រមព្រៀង។

២. សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះអាចបញ្ជូនករណីកំហុសវិជ្ជាជីវៈនេះទៅអង្គភាពមានសមត្ថកិច្ច។

៣. មេធាវីបរទេសដែលបំពេញវិជ្ជាជីវៈនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ដែលត្រូវទទួលរងការដាក់វិន័យដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អាចប្ដឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ ក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ បន្ទាប់ពីបានទទួលដំណឹងអំពីសេចក្ដីសម្រេចរបស់គណៈមេធាវី។ បណ្ដឹងឧទ្ធរណ៍នេះត្រូវព្យួរការអនុវត្តន៍សេចក្ដីសម្រេច លើកលែងតែអង្គបុរេជំនុំជម្រះសម្រេចផ្សេងទៀត។ សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះបិទផ្លូវប្ដឹងតវ៉ា។

៤. នៅពេ លដែលទទួលបានលទ្ធផលនៃការដាក់វិន័យនេះ មេធាវីដែលបានលុបឈ្មោះចេញពីបញ្ជីមេធាវី ដើម្បីការពារក្ដីនៅចំពោះអង្គជំនុំជម្រះវិសាមញ្ញ ត្រូវប្រគល់សម្ភារៈទាក់ទងទៅនឹងរឿងក្ដីទាំងអស់ ទៅអង្គភាពពាក់ព័ន្ធនៃការិយាល័យរដ្ឋបាល ដើម្បីធានាដល់និរន្តភាពក្នុងការការពារក្ដី។

១៨. មាត្រា ២១(៣) នៃកិច្ចព្រមព្រៀងបានចែងបន្ថែមទៀតថា:

"មេធាវីណាដែលមានសញ្ជាតិខ្មែរឬមិនមែនខ្មែរ ដែលត្រូវជួលឬចាត់តាំងឲ្យធ្វើការជាមួយជនសង្ស័យ ឬជនជាប់ចោទក្នុងការការពារកូនក្ដីរបស់ខ្លួន ត្រូវអនុវត្តតាមកិច្ចព្រមព្រៀងនេះ ច្បាប់កម្ពុជាស្ដីពីលក្ខន្តិកៈមេធាវី បទដ្ឋាន និងសីលធម៌នៃវិជ្ជាជីវៈច្បាប់ ដែលគេទទួលស្គាល់"។

១៩. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញបន្ថែមទៀតថា មាត្រា ៦(១) និង ២៤(២) និង (៣) នៃក្រមសីលធម៌មេធាវីដែលទទួលបានសិទ្ធិប្រកបវិជ្ជាជីវៈពីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដែលចែងថាៈ

"មាត្រា ៦៖ គោលការណ៍ជាសារវន្ត
នៅគ្រប់កាលៈទេសៈ មេធាវីត្រូវគោរពពាក្យសម្បថរបស់ខ្លួន និងត្រូវគោរពគោលការណ៍ សម្បជញ្ញៈ មនុស្សធម៌ និងភាពថ្លៃថ្នូរ។

"មាត្រា ២៤០: ទំនាក់ទំនងជាមួយចៅក្រម

[...]

មេធាវីត្រូវសម្តែងចំពោះចៅក្រមនូវការគោរពទៅតាមមុខងារ ក្នុងភាពឯករាជ្យ និងថ្លៃថ្នូរ។

មេធាវីត្រូវគោរពតាមវិធាននៃនីតិវិធី ហើយនិងទម្លាប់របស់តុលាការ។ មេធាវីមិនត្រូវប្រើវិធីមិនស្មោះត្រង់និងរាំងស្ទះជាដាច់ខាត ជាពិសេសពាក់ព័ន្ធនឹងការប្រឆាំងជំទាស់។ មេធាវី មានសិទ្ធិសម្តែងឡើងនូវអ្វីៗដែលខ្លួនយល់ថាមានប្រយោជន៍ដល់អតិថិជនរបស់ខ្លួន"។

២០. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ICTY) នៅពេលដែលមានការពាក់ព័ន្ធនឹងបទបញ្ញត្តិដែលស្រដៀងគ្នាយ៉ាងខ្លាំងទៅនឹងវិធាន ៣៨ នៃ វិធានផ្ទៃក្នុងនោះ បានយ ល់ឃើញថា វិធាននេះ "មានន័យទាក់ទងទៅនឹងបញ្ហាចរិយាមាយាទនៅក្នុងសាលសវនាការ ឬក៏ឥរិយាបថផ្សេងទៀតនៅក្នុងការប្រព្រឹត្តិទៅនៃកិច្ចដំណើរការនីតិវិធីដែលធ្វើឲ្យវិធាននោះមានលក្ខណៈចាំបាច់ក្នុងការធានាថា មេធាវីមិនមានវេទិកានៅក្នុងសវនាការ ដើម្បីបន្តនូវការប្រព្រឹត្តិដែលមានលក្ខណៈរាំងស្ទះរបស់គាត់នោះឡើយ"[17]។

២១. លើសពីនេះទៀត នៅក្នុង "សេចក្តីសម្រេចអំពីការចាត់តាំងមេធាវី" សម្រាប់ Vojislav Seselj អង្គជំនុំជម្រះសាលាដំបូងនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី បានលើកឡើងថាៈ

---

[17] *រឿងក្តីរដ្ឋអាជ្ញា តទល់ Kunarac និងអ្នកផ្សេងទៀត*, IT-96-23&23/1, "សេចក្តីសម្រេចលើសំណើរបស់ជនជាប់ចោទ Radomir Kovac ដើម្បីអនុញ្ញាតឲ្យលោក Milan Vujin ធ្វើជាសហមេធាវីមនុស្សធម៌", ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០០ កថាខណ្ឌទី៨ យោងមាត្រា៤៦ នៃវិធាននីតិវិធីនិងភស្តុតាងរបស់ ICTY។

"២៤. [...] នៅពេលដែលសមាសភាព និងមុខងាររបស់តុលាការអាចរងនូវការរិះគន់នោះ តុលាការសិទ្ធិមនុស្សអឺរ៉ុបបានលើកឡើងថា អំពើវាយប្រហារដោយសារតែបញ្ហាផ្ទាល់ខ្លួន ដែលធ្វើឡើងប្រឆាំងនឹងចៅក្រម ដែលបានបង្កើតនូវបរិយាកាសដែលខូចប្រយោជន៍ដល់ការគ្រប់គ្រងយុត្តិធម៌ដ៏មានសណ្តាប់ធ្នាប់នោះ អាចជាកម្មវត្ថុនៃការដាក់ទណ្ឌកម្ម។ តុលាការបាននិយាយថា:

> "អង្គជំនុំជម្រះសូមរំលឹកផងដែរថាសកម្មភាពរបស់សាលាជម្រះក្តី ដែលសកម្មភាពនេះមានគោលដៅធានានូវការស្វែងរកយុត្តិធម៌ និងមានសារៈសំខាន់ណាស់ ក្នុងកិច្ចដំណើរការនៃនីតិរដ្ឋ ត្រូវតែទទួលបាននូវការផ្តល់សេចក្តីទុកចិត្តពីសាធារណជន ហើយចៅក្រមផ្ទាល់ ក៏ត្រូវទទួលបាននូវការផ្តល់សេចក្តីទុក្ខចិត្តនេះ ដើម្បី បំពេញតួនាទីរបស់ខ្លួនបាន។ វាជាការចាំបាច់ដែលត្រូវមានវិធានការការពារចៅក្រមពីការវាយប្រហារផ្នែកពាក្យសម្តីនានា នៅពេលដែលចៅក្រមកំពុងបំពេញភារកិច្ចរបស់ខ្លួននោះ"។[18]

២៥. ក្នុងករណីចាំបាច់ នៅក្នុងការពិចារណាលើការហាមឃាត់ដែលអាចត្រូវបានគិតទៅលើសិទ្ធិក្នុងការតំណាងឲ្យខ្លួនឯងរបស់ជនត្រូវចោទ ដែលរួមបញ្ចូលទាំងការនាំចេញពីបន្ទប់សវនាការផងដែរ បើសិនជាចាំបាច់ អង្គជំនុំជម្រះមិនអាចធ្វើអ្វីបានទេ ក្រៅតែពីយល់ព្រមចំពោះការវាយតម្លៃភាពយុត្តិធម៌របស់ Douglas នៅក្នុងរឿងក្តី *Allen* ថា "បន្ទប់សវនាការ គឺជាកន្លែងដ៏សក្តិសមដែលការកាត់សេចក្តីត្រូវដំណើរការដោយភាពថ្លៃថ្នូរ ហើយមិនមែនជាកន្លែងអ្នកចូលរួមអាចមានឱកាសសម្រាប់ការកំសាន្តនោះទេ"[19]។

---

[18] ការបកប្រែជាភាសាអង់គ្លេស:

""The Court recalls that, the courts, being the guarantors of justice and essential to the rule of law, must enjoy public confidence, and that the judges must enjoy such confidence in conditions free of any perturbation if they are to be successful in performing their tasks. It may therefore prove necessary to protect them from offensive verbal attacks when on duty."

[19] *រឿងក្តីរដ្ឋអាជ្ញា តទល់ Seselj,* IT-03-67-PT, "សេចក្តីសម្រេចលើការចាត់តាំងមេធាវី", អង្គជំនុំជម្រះ I, ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៦, កថាខណ្ឌទី២៤-២៥។ សូមមើលផងដែរ *រឿងក្តីរដ្ឋអាជ្ញា តទល់ Blagojevic,* IT-02-60-T, "សេចក្តីសម្រេចលើសំណើសុំឈប់សម្រាកដើម្បីអាចឆ្លើយតបទៅនឹងសារណាចុងក្រោយរបស់សហព្រះរាជអាជ្ញា", អង្គជំនុំជម្រះ I, ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០៤ ដែលមេធាវីរបស់ Vidoje Blagojevic ត្រូវបាន "ព្រមាន" ចំពោះការដែលបានធ្វើការចោទប្រកាន់ដោយមិនមានការគាំទ្រទាក់ទងនឹងវិជ្ជាជីវៈ និងក្រមសីលធម៌របស់សមាជិកនៃក្រុមចោទប្រកាន់ទោស។



ការព្រមានចំពោះសហមេធាវីអន្តរជាតិ

២២. ពាក់ព័ន្ធនឹងពាក្យសុំ ដែលមាន "ពាក្យសម្ដីឬការនិយាយមួយចំនួនដែលមានលក្ខណៈរំលោភបំពាន និង ប្រមាថ" ដោយជនត្រូវចោទដែលមិនមានអ្នកតំណាងនោះ ការិយាល័យនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី បាននិយាយថាៈ

> "ភាគីដែលបង្ហាញខ្លួនចំពោះមុខតុលាការ មានសេរីភាពក្នុងការរៀបចំពាក្យសម្ដី ដើម្បីឆ្លើយ។ ទោះបីជាយ៉ាងណា សេរីភាពនោះមិនមែនគ្មានដែនកំណត់នោះទេ។ ការប្រមាថមើលងាយ ពុំមែនជាទម្លាប់ករណី [...] នោះទេ សំណើនានាដែលប្រើពាក្យបែបបំពាននិងប្រមាថមើលងាយ នៅក្នុងពាក្យសុំនេះ គឺពិតជា "ឥតបានការ ឬជាការបំពានទៅលើរឿងក្ដី" [...]"[20]។

២៣. អង្គជំនុំជម្រះសាលាដំបូងនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី បានរំលឹកឡើងវិញផងដែរថា "តុលាការមានការយកចិត្តទុកដាក់ជាធម្មានុរូបក្នុងការធានាថា ការកាត់ទោសដំណើរការដោយមានពេលវេលាកំណត់ដោយគ្មានការអាក់ខាន ការពន្យារពេល ឬការរាំងស្ទះ"[21]។

"ការរាំងស្ទះដល់ការកាត់ទោស ទោះបីស្ថិតនៅក្នុងកាលៈទេសៈណាក៏ដោយ អាចធ្វើឱ្យកើតមានហានិភ័យនៃការផ្ដោះផ្ដោយក្នុងការទទួលបានភាពយុត្តិធម៌ ពីព្រោះដំណើរការនីតិវិធីទាំងមូលមិនត្រូវបានប្រព្រឹត្តទៅនឹងសម្រេចសេចក្ដីដោយភាពយុត្តិធម៌"[22]។ ជាពិសេស នេះគឺជាករណីដែលជនត្រូវចោទត្រូវបានគេបន្តការឃុំខ្លួនៈ

> "នៅពេលដែលជនត្រូវចោទត្រូវគេដកហូតសិទ្ធិសេរីភាព ហើយស្ថិតនៅក្នុងការឃុំឃាំងរបស់តុលាការអន្តរជាតិ វាជាការសមស្របសម្រាប់អង្គជំនុំជម្រះសាលាដំបូង ក្នុងការតម្រូវឱ្យមានភាពបន្ទាន់និងភាពសមគួរក្នុងកម្រិតខ្ពស់ជាងនេះ នៅក្នុងការជំនុំជម្រះរឿងក្ដី។ ជនត្រូវចោទ ដែលត្រូវបានឃុំខ្លួនមានសិទ្ធិធ្វើឱ្យរឿងក្ដីរបស់ខ្លួនមានអាទិភាព គាត់នៅតែជាមនុស្សដែលគ្មានទោស ជាមនុស្សដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋធ្ងន់ធ្ងរ រហូតដល់ពេលដែលរកឃើញថាគាត់មានពិរុទ្ធ។ បន្ទាប់ពី

---

[20] *រឿងក្ដីរដ្ឋអាជ្ញា តទល់ Seselj,* IT-03-67-PT, "សេចក្ដីសម្រេចលើញត្តិសុំមោឃភាព", Bureau, ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៣, កថាខណ្ឌ៥។

[21] *រឿងក្ដីរដ្ឋអាជ្ញា Seselj,* IT-03-67-PT, "សេចក្ដីសម្រេចលើញត្តិចោទប្រកាន់ទោស ចំពោះដីកាតែងតាំងមេធាវី ដើម្បីជួយVojislav Seselj និងក្រុមការពារក្ដីរបស់គាត់", អង្គជំនុំជម្រះII, ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០០៣, កថាខណ្ឌទី២១។

[22] *រឿងក្ដីរដ្ឋអាជ្ញា តទល់ Milosevic,* IT-02-54-T, "ហេតុផលចំពោះសេចក្ដីសម្រេចលើការចាត់តាំងមេធាវីការពារក្ដី", អង្គជំនុំជម្រះ, ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៤, កថាខណ្ឌទី៣៣។



PRE-TRIAL CHAMBER

បានទទួលបញ្ហានេះ អង្គជំនុំជម្រះសាលាដំបូងមានតួនាទីច្រើន ដែលក្នុងចំណោមនោះមានការធានាថាព្រះរាជអាជ្ញាកាន់រឿងក្តីនៅក្នុងលក្ខណៈមួយដែលត្រឹមត្រូវនិងឆាប់រហ័ស និងមិនបង្កព្យសនកម្មលើសិទ្ធិរបស់ជនត្រូវចោទស្របតាមមាត្រា ២១ នៃច្បាប់លក្ខន្តិកៈ ឬបទបញ្ញត្តិនានានៅក្នុងវិធានផ្ទៃក្នុង”[23]។

២៤. ស្រដៀងគ្នានេះ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការពិសេសសម្រាប់សេរ៉ាឡេអូន បាននិយាយថា:

> “យើងចង់អះអាងនៅទីនេះថា អង្គជំនុំជម្រះសាលាដំបូងមិនអាចអនុញ្ញាតឱ្យភាពថ្លៃថ្នូរនៃដំណើរការនីតិវិធីរបស់ខ្លួនត្រូវបានធ្វើឱ្យល្អក់កករ ឬត្រូវបានប្រព្រឹត្តឡើងនៅក្នុងលក្ខណៈ ដែលមិនស្របនឹងសេចក្តីប្រាថ្នាតាមវិធាននៃដំណើរការតុលាការនោះឡើយ។ ជាបញ្ហាច្បាប់ វាជាភារៈកិច្ចរបស់យើងក្នុងនាមជាអង្គជំនុំជម្រះ ដែលត្រូវការពារភាពថ្លៃថ្នូរនៃដំណើរការ នីតិវិធីគ្រប់ពេលវេលានៅចំពោះមុខយើង និងត្រូវធានាថា ការគ្រប់គ្រងភាពយុត្តិធម៌មិនត្រូវបាននាំទៅរកកេរ្តិ៍ឈ្មោះអាក្រក់នោះទេ”[24]។

២៥. ដោយគិតដល់យុត្តិសាស្ត្ររបស់តុលាការអន្តរជាតិ អង្គបុរេជំនុំជម្រះពិចារណាឃើញថា វិធាន៣៨ នៃវិធានផ្ទៃក្នុង មានអត្ថន័យដែលធានាថា ដំណើរការនីតិវិធីមិនត្រូវបានរាំងស្ទះដោយឥរិយាបថប្រមាថមើលងាយ និង/ឬ បង្អាក់ ឬដោយការប្រព្រឹត្តិណាមួយ ដែលរាប់ថាជាការបំពាន លើរឿងក្តីនោះទេ ពីព្រោះការប្រព្រឹត្តិនោះនាំឱ្យមានគ្រោះថ្នាក់ដល់ការគ្រប់គ្រងភាពយុត្តិធម៌។ អង្គជំនុំជម្រះបានឯកភាពតាមការយល់ឃើញរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប ដែលអង្គជំនុំជម្រះសាលាដំបូងនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី បានយកមកអនុវត្ត ដើម្បីធានាថា “នៅពេលដែលសមាសភាព និងមុខងាររបស់តុលាការអាចត្រូវបានរិះគន់នោះអំពើវាយប្រហារ ដោយសារតែបញ្ហាផ្ទាល់ខ្លួនធ្វើឡើងប្រឆាំងនឹងចៅក្រម ដែលបានបង្កើតនូវបរិយាកាស ដែលខូចប្រយោជន៍ ដល់ការគ្រប់គ្រងយុត្តិធម៌ដ៏មានសណ្តាប់ធ្នាប់នោះ អាចជាកម្មវត្ថុនៃការដាក់ទណ្ឌកម្ម”[25] ដូចដែលមានចែងនៅក្នុងវិធាន៣៨ នៃវិធានផ្ទៃក្នុង។ អង្គបុរេជំនុំជម្រះបានពិចារណាឃើញថែមទៀតថា ភាសាប្រមាថមើលងាយក៏ដូចជាវិធីសាស្ត្រ ដែលត្រូវ

---

[23] *រឿងក្តីរដ្ឋអាជ្ញា តទល់ Furundzija,* IT-95-17/1-PT, ចុះថ្ងៃទី៥ ខែមិថុនា ឆ្នាំ១៩៩៨, កថាខណ្ឌទី៥។

[24] *រឿងក្តីរដ្ឋអាជ្ញា តទល់ Norman និងអ្នកផ្សេងទៀត.*, SCSL-04-14-T, “សេចក្តីសម្រេចលើ ពាក្យសុំរបស់ Samuel Hinga Norman ចំពោះការតំណាងខ្លួន ក្រោមមាត្រា ១៧(៤)(d) នៃលក្ខន្តិកៈតុលាការពិសេស”, អង្គជំនុំជម្រះ, ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០០៤, កថាខណ្ឌទី២៨។

[25] *Prosecutor v. Seselj*, IT-03-67-PT, “Decision on Assignment of Counsel”, Trial Chamber I, 21 August 2006, para. 24, quoted at para. 21 of the current Warning.

បានប្រើប្រាស់ ដើម្បីពន្យារពេលដំណើរការនីតិវិធីអាចចាត់ទុកជាការបំពានលើដំណើរការតុលាការ និងប៉ះពាល់ដល់ភាពយុត្តិធម៌នៃដំណើរការនីតិវិធី។ នៅក្នុងកាលៈទេសៈបែបនេះ អង្គបុរេជំនុំជម្រះមានភារកិច្ចការពារភាពថ្លៃថ្នូរដំណើរការនីតិវិធី។

២៦. អង្គបុរេជំនុំជម្រះរំលឹកថា សវនាការលើបណ្តឹងឧទ្ធរណ៍ដំបូង ដែលប្តឹងដោយជនត្រូវចោទប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ន ត្រូវបានពន្យារពេលដោយសារតែលោក Vergès បានបដិសេធមិនបន្តការពារក្តីក្នុងនាមជនត្រូវចោទទៀតទេ ដោយមូលហេតុថា ឯកសារទាំងអស់នៅក្នុងសំណុំរឿង មិនអាចអានជាភាសាបារាំងបានទេ។ នៅក្នុង "សេចក្តីសម្រេចលើពាក្យសុំពន្យារពេលសវនាការ អំពីបណ្តឹងឧទ្ធរណ៍លើការឃុំខ្លួនបណ្តោះអាសន្ន" អង្គបុរេជំនុំជម្រះបានកត់សម្គាល់ឃើញថា:

> "លក្ខខណ្ឌដែលនាំទៅដល់ការដកខ្លួនរបស់សហមេធាវីអន្តរជាតិ មានតាំងពីពេលដែលគាត់ការពារក្តីដំបូងម្ល៉េះ។ ពុំមានពាក្យសុំពន្យារពេលណាមួយ ឬបណ្តឹងណាមួយពាក់ព័ន្ធនឹងបញ្ហាភាសាត្រូវបានដាក់ជូនអង្គបុរេជំនុំជម្រះនោះទេ។ ការបដិសេធបន្តការពារក្តីលើបណ្តឹងឧទ្ធរណ៍របស់គាត់នេះ ត្រូវបានគេប្រកាសជូនដំណឹងដំបូងនៅថ្ងៃសវនាការ ហើយបានធ្វើឱ្យកូនក្តីរបស់គាត់ មិនអាចមានការជជែកដេញដោលលើបណ្តឹងឧទ្ធរណ៍របស់គាត់ ឱ្យបានឆាប់រហ័សនោះទេ។ ចំណុចនេះបានរំលោភលើសិទ្ធិជាមូលដ្ឋានរបស់ជនត្រូវចោទ ក្នុងការទទួលបាននូវសវនាការទាន់ពេលវេលា និងលើការតំណាងរបស់មេធាវីដែលគាត់បានជ្រើសរើស ដែលជាសិទ្ធិដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ និងដែលយកមកអនុវត្តនៅអង្គជំនុំជម្រះវិសាមញ្ញ"[26]។

២៧. អង្គបុរេជំនុំជម្រះបានដាក់ការព្រមានចំពោះសហមេធាវីអន្តរជាតិ ដោយលើកឡើងថា:

> "ជាលទ្ធផលនៃឥរិយាបថរបស់សហមេធាវីអន្តរជាតិ ដែលបានណែនាំដោយគ្មានការជូនដំណឹងថា គាត់នឹងមិនបន្តការពារក្តីលើបណ្តឹងឧទ្ធរណ៍នេះទៀតទេនៅក្នុងកាលៈទេសៈ ដូចបានលើកឡើងខាងលើនោះ ការព្រមានត្រូវបានធ្វើចំពោះគាត់ អនុលោមតាមវិធាន ៣៨(១) នៃវិធានផ្ទៃក្នុង នៅពេលដែលគាត់បានបំពានលើដំណើរការរបស់អង្គបុរេជំនុំជម្រះ និងសិទ្ធិរបស់ជនត្រូវចោទ"[27]។

---

[26] សេចក្តីសម្រេចលើសំណើសុំពន្យារពេលសវនាការលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន, ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៨, C26/I/25, កថាខណ្ឌទី១១។

[27] សេចក្តីសម្រេចលើសំណើសុំពន្យារពេលសវនាការលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន, កថាខណ្ឌទី១៥។

២៨. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ទោះបីជាសវនាការថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៩ ត្រូវបានលើកពេលដើម្បីអនុញ្ញាតឱ្យគាត់បានចូលរួមក៏ដោយ លោក Vergès មិនបានបង្ហាញនូវសេចក្តីសន្និដ្ឋានផ្ទាល់មាត់ណាមួយពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ ឬបានរួមចំណែកដល់ការពិភាក្សាដេញដោលប្រកបដោយអត្ថន័យនៅចំពោះមុខអង្គបុរេជំនុំជម្រះនៅក្នុងពេលសវនាការ ដែលបានបន្តនៅថ្ងៃទី៣ ខែមេសា ឆ្នាំ ២០០៩ នោះឡើយ។

២៩. ការចូលរួមរបស់លោក Vergès នៅក្នុងសវនាការ គឺមានតែការនិយាយក្រៅពីវិសាលភាពនៃបណ្តឹងឧទ្ធរណ៍ និងហួសព្រំដែននៃសិទ្ធិក្នុងការឆ្លើយតប។ អត្ថាធិប្បាយរបស់លោក Vergès មានបំណងជជែកអំពីភាពថ្លៃថ្នូរ និងធម្មានុរូបភាពរបស់តុលាការជាទូទៅ និងអំពីចៅក្រមនៃអង្គបុរេជំនុំជម្រះជាពិសេស។

៣០. ការលើកឡើងដោយគ្មានខ្លឹមសាររបស់លោក Vergès និងភាសាដែលគាត់បានប្រើ គឺជាការប្រមាថមើលងាយចំពោះចៅក្រមនៃអង្គបុរេជំនុំជម្រះ។ ការលើកឡើងដែលបានធ្វើក្រៅពីបរិបទនៃបណ្តឹងឧទ្ធរណ៍ និងហួសពីវិសាលភាពនៃការអនុញ្ញាតឱ្យឆ្លើយតបទាំងនេះ ចាត់ទុកជាការប្រព្រឹត្តអំពើប្រមាថមើលងាយ និងរាំងស្ទះ ដែលមានចែងនៅក្នុងវិធាន ៣៨ នៃវិធានផ្ទៃក្នុង។ អង្គបុរេជំនុំជម្រះ មិនអាចអត់អោនឱ្យបានទេ ដោយសារអង្គបុរេជំនុំជម្រះជាអ្នកមានភារៈកិច្ចធានាឱ្យមានសុភាវធម៌ និងភាពថ្លៃថ្នូរ ដែលចាំបាច់សម្រាប់ដំណើរការនីតិវិធីតុលាការ។

៣១. លើសពីនេះទៀត ចាប់តាំងពីពេលដែលលោក Vergès បង្ហាញខ្លួននៅចំពោះមុខអង្គបុរេជំនុំជម្រះ កាលពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៨ គាត់បានបដិសេធមិនចូលរួមប្រកបដោយអត្ថន័យនៅ ក្នុងសវនាការនានា ហើយនៅពេលមួយគាត់បានខកខានមិនបានចូលរួមចំណែកដល់ការពិភាក្សាដេញដោលនោះ ទោះបីជាសវនាការនោះត្រូវបានស្នើសុំយ៉ាងជាក់លាក់ពីសហមេធាវីការពារក្តី និងត្រូវបានពន្យារពេលដើម្បីអនុញ្ញាតឱ្យលោក Vergès បានចូលរួមក៏ដោយ។ ឥរិយាបថនេះបាននាំឱ្យមានការពន្យារពេលដំណើរការនីតិវិធី និងមានការប្រើប្រាស់ធនធានរបស់តុលាការខុស។ ជាមួយនឹងសម្តីរបស់គាត់ដូចបានពិភាក្សាខាងលើឥរិយាបថរបស់លោក Vergès មានតម្លៃស្មើនឹងការប្រព្រឹត្តការរាំងស្ទះ និងការបំពានលើដំណើរការយោងតាមអត្ថន័យនៃវិធាន៣៨ នៃវិធានផ្ទៃក្នុង។

00328091

C26/5/22

០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ១៤ និង១៥)

# ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆ័ន្ទ:

**ព្រមាន** លោក Jacques Vergès ថា ប្រសិនបើការប្រព្រឹត្តិរបស់គាត់នៅតែជាការប្រមាថមើលងាយ ឬម្យ៉ាងទៀតនៅតែជាការបំពាន ឬប្រសិនបើគាត់រាំងស្ទះដល់ដំណើរការនីតិវិធី ឬជ្រើសរើសធ្វើទង្វើដែលមានតម្លៃស្មើនឹងការបំពានលើរឿងក្តីនោះ អង្គជំនុំជម្រះនឹងដាក់ទណ្ឌកម្មគាត់ ដោយអនុលោមតាមវិធាន៣៨ នៃវិធានផ្ទៃក្នុង។

**បង្គាប់** ឲ្យក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះ ផ្ញើការព្រមាននេះមួយច្បាប់ជូនទៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា គណៈមេធាវីទីក្រុងប៉ារីស និងអង្គភាពគាំពារការការពារក្តី។

ភ្នំពេញ ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៩

**ប្រធានអង្គបុរេជំនុំជម្រះ**

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

**ប្រាក់ គឹមសាន**